**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

CAMFEBA
IN
No. 0300
Date: 18/Dec/2015
From:
Time: 10:00 A.M
Received by: MoM
Att:

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ៤៦៧ **ក.ប**/ប្រ.ក

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការជ្រើសរើសកម្មករនិយោជិតវ័យក្មេង នៅតាមសហគ្រាស គ្រឹះស្ថាន

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ១៣៨ នៃអង្គការអន្តរជាតិខាងការងារ ស្តីពីអាយុអប្បបរមាអាចចូលធ្វើការបាន
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់នីតិវិធីនៃការជ្រើសរើសកម្មករនិយោជិតវ័យក្មេងនៅតាមសហគ្រាស រោងចក្រ គ្រឹះស្ថាន។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

**ប្រការ ២.-**

កម្មករនិយោជិតវ័យក្មេងសំដៅទៅលើកុមារ ដែលមានអាយុអប្បបរមាអាចចូលបម្រើការងារបាន ចាប់ពីអាយុ១៥ឆ្នាំ ទៅក្រោម១៨ឆ្នាំ ដូចដែលមានចែងក្នុងមាត្រា១៧៧ នៃច្បាប់ស្តីពីការងារ។

**ប្រការ ៣.-**

នីតិវិធីនៃការជ្រើសរើសកម្មករនិយោជិតវ័យក្មេង មានគោលដៅកំណត់លក្ខខណ្ឌការងារសមរម្យអាចអនុញ្ញាតឱ្យកម្មករនិយោជិតវ័យក្មេងធ្វើការងារបាន លុះត្រាតែការងារទាំងនោះមិនធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាព និងការរីកលូតលាស់នៃរាងកាយ ផ្លូវចិត្ត និងមិនប៉ះពាល់ដល់ការចូលរៀននៅក្នុងសាលារៀន ឬការចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលនានារបស់ពួកគេឡើយ។

**ប្រការ ៤.-**

ហាមនិយោជកនៃសហគ្រាស រោងចក្រ គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ប្រើប្រាស់កុមារដែលមានអាយុពី១៥ឆ្នាំ ទៅក្រោម១៨ឆ្នាំ នៅក្នុងលក្ខខណ្ឌការងារប្រកបដោយគ្រោះថ្នាក់ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ កម្មករនិយោជិតវ័យក្មេងអាចចូលបម្រើការងារបាន លុះត្រាតែបំពេញតាមនីតិវិធីដូចមានចែងក្នុងប្រការ ៥ ៦ និងប្រការ៧ នៃប្រកាសនេះ។

**ប្រការ ៥.-**

និយោជកមុនពេលជ្រើសរើសកម្មករនិយោជិតវ័យក្មេង ឱ្យចូលបម្រើការងារនៅក្នុងសហគ្រាស រោងចក្រ គ្រឹះស្ថាន ត្រូវអនុវត្តដូចតទៅៈ

- និយោជកត្រូវត្រួតពិនិត្យឯកសារឱ្យបានត្រឹមត្រូវយ៉ាងហោចណាស់ចំនួន៣ ក្នុងចំណោមឯកសារដូចខាងក្រោមៈ
    - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
    - សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ
    - សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬសេចក្តីចម្លងសំបុត្រកំណើត
    - លិខិតបញ្ជាក់សញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សា
- និយោជកត្រូវសម្ភាសន៍ជាមួយកម្មករនិយោជិតវ័យក្មេង ដោយមានការដឹងឮ និងធានាអះអាងពីមាតា បិតា ឬអាណាព្យាបាល ដើម្បីផ្ទៀងផ្ទាត់ និងវាយតម្លៃឯកសារ និងលក្ខណៈរូបសាស្ត្ររបស់កម្មករ និយោជិតវ័យក្មេង
- និយោជកត្រូវមានកិច្ចសន្យាការងារដែលមានការយល់ព្រមពីមាតា បិតា ឬអាណាព្យាបាលរបស់កម្មករនិយោជិតវ័យក្មេង ស្របតាមមាត្រា១៨១នៃច្បាប់ស្តីពីការងារ
- ក្នុងករណីសង្ស័យអំពីកម្មករនិយោជិតមានអាយុក្រោមច្បាប់កំណត់ និយោជកត្រូវបញ្ជូនឯកសារមកនាយកដ្ឋានការងារកុមារ និងនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបញ្ជាក់អត្តសញ្ញាណ កាយសម្បទា និងលក្ខខណ្ឌសុខភាពដែលអាចអនុញ្ញាតឱ្យធ្វើការបាន
- និយោជកត្រូវបញ្ជូនសំណុំឯកសារ ក្នុងនោះត្រូវមានបញ្ជីរាយនាមកម្មករនិយោជិតវ័យក្មេង និងពាក្យស្នើសុំទិដ្ឋាការ មកនាយកដ្ឋានការងារកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់ការអនុញ្ញាតប្រើប្រាស់កម្មករនិយោជិតវ័យក្មេង
- និយោជកត្រូវមានសៀវភៅបញ្ជីសម្រាប់ចុះនាមកម្មករនិយោជិតវ័យក្មេង ដែលមានអាយុចាប់ពី១៥ឆ្នាំដល់ក្រោម១៨ឆ្នាំ ប្រចាំនៅសហគ្រាស រោងចក្រ គ្រឹះស្ថាន។

**ប្រការ ៦.-**

ក្នុងអំឡុងពេលដែលកម្មករនិយោជិតវ័យក្មេងចូលធ្វើការ និយោជកនៃសហគ្រាស រោងចក្រ គ្រឹះស្ថាន ត្រូវគោរពនីតិវិធីដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិ ច្បាប់ស្តីពីការងារ និងប្រកាសពាក់ព័ន្ធពលកម្មកុមារ ដូចខាងក្រោមៈ

- មិនត្រូវឱ្យធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- ត្រូវធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈឱ្យបានត្រឹមត្រូវ
- មិនអនុញ្ញាតឱ្យធ្វើការបន្ថែមម៉ោង ធ្វើការនៅថ្ងៃអាទិត្យ ថ្ងៃឈប់សម្រាក និងធ្វើការពេលយប់ចន្លោះ ពីម៉ោង២២:០០ដល់ម៉ោង៥:០០ភ្លឺ
- និយោជកត្រូវគោរពទៅតាមបទប្បញ្ញត្តិ និងបទដ្ឋាននានាដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ ជាធរមាន។

**ប្រការ ៧.-**

ក្រោយពេលកម្មករនិយោជិតវ័យក្មេងទទួលបានការងារ និយោជក និយោជិត ប្រតិភូបុគ្គលិក សហជីព និងភាគីពាក់ព័ន្ធត្រូវអនុវត្ត ដូចតទៅៈ

- និយោជកត្រូវតម្កល់ទុកឯកសារ បញ្ជីស្នាម និងលិខិតបញ្ជាក់នានា ដើម្បីសម្រួលដល់អាជ្ញាធរ ឬ សមត្ថកិច្ចធ្វើការត្រួតពិនិត្យតាមដានកម្មករនិយោជិតវ័យក្មេងនេះ
- យ៉ាងហោចណាស់មួយឆ្នាំម្តង ចាប់ផ្តើមពីចូលបម្រើការងារ រហូតដល់កម្មករនិយោជិតវ័យក្មេង អាយុ១៨ឆ្នាំ ត្រូវពិនិត្យសុខភាពឱ្យបានត្រឹមត្រូវ និងបញ្ជាក់ដោយនាយកដ្ឋានពេទ្យការងារ នៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ករណីសង្ស័យកុមារមានសភាពស្លេកស្លាំង សុខភាពទ្រុឌទ្រោម ឬអាចប្រឈមនឹងគ្រោះថ្នាក់ការងារ ដោយប្រការណាមួយ និយោជកត្រូវដកហូតកម្មករនិយោជិតវ័យក្មេងជាបន្ទាន់ និងត្រូវផ្តល់ការស្តារ នីតិសម្បទា ដើម្បីកុមារត្រឡប់មកទទួលការងារសមរម្យ។
- និយោជិត ប្រតិភូបុគ្គលិក សហជីព និងភាគីពាក់ព័ន្ធត្រូវចូលរួមរាយការណ៍មកនាយកដ្ឋានការងារ កុមារក្នុងករណីសង្ស័យខាងលើ ដើម្បីការពារឧត្តមប្រយោជន៍កុមារ។

**ប្រការ ៨.-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយណានៃប្រកាសនេះ ត្រូវពិន័យឬទទួលទោសដូចមានចែង ក្នុងជំពូកទី១៦នៃច្បាប់ស្តីពីការងារ។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង ស្ថាប័នពាក់ពន្ធ័
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធសហជីព
- ឯកសារ កាលប្បវត្តិ